**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ២៩ សីហា ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Aug-2012, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី ក.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសម្លេង នានាទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨**

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ុរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

ចៅក្រមបម្រុង ធូ មន្នី

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមតាមវិធាន ៩៣ និង ២១ នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធាន”) សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងសុំការបញ្ជាក់ពីការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសម្លេង នៃការស្តាប់ចម្លើយសាក្សី អឿន តាន ដោយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨។ សំណើនេះជាការចាំបាច់ដោយសារ អឿន តាន បានផ្តល់សក្ខីកម្មថា កិច្ចសម្ភាសន៍សួរនិងឆ្លើយដោយពុំបានធ្វើកំណត់ហេតុជាសំឡេងរយៈពេលពេញមួយថ្ងៃជាមួយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ត្រូវបានធ្វើឡើងមួយថ្ងៃ មុនការស្តាប់ចម្លើយដោយបានធ្វើកំណត់ហេតុជាសំឡេងជាមួយអ្នកស៊ើបអង្កេតដដែលទាំងនោះ[1]។ អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមដាក់សំណើជាពិសេសនេះទៅអង្គជំនុំជម្រះសាលាដំបូងស្នើឲ្យ ក.ស.ច.ស ធ្វើការបញ្ជាក់ថា៖ **ក**.តើមានកំណត់ហេតុជាសំឡេង វីដេអូ និង/ឬ ជាលាយលក្ខណ៍អក្សរស្តីអំពីកិច្ចសម្ភាសន៍សួរនិងឆ្លើយរវាង អឿន តាន និងអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ឬមិនមាន **ខ**.រយៈពេលនៃកិច្ចសម្ភាសន៍សួរនិងឆ្លើយនោះ **គ**.បុគ្គលដែលមានវត្តមាននៅពេលនោះ **ឃ**.ឯកសារ និងសម្ភារៈផ្សេងទៀត ដែលបានបង្ហាញដល់ អឿន តាន ប្រសិនបើមាន និង **ង**.ប្រសិនបើគ្មានកំណត់ហេតុនៃកិច្ចសម្ភាសន៍សួរនិងឆ្លើយនោះទេ សូមបញ្ជាក់ពីមូលហេតុដែលពុំបានធ្វើកំណត់ហេតុ និងពីមូលហេតុនៃការសួរ អឿន តាន ពេញមួយថ្ងៃ ដោយពុំបានធ្វើកំណត់ហេតុអំពីការសាកសួរនោះ មុនពេលមានការស្តាប់ចម្លើយដោយបានធ្វើកំណត់ហេតុ[2]។ សំណើនេះត្រូវបានធ្វើឡើងដោយសុទ្ធចិត្ត និងដើម្បីជាប្រយោជន៍យុត្តិធម៌តែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាក៏បានយល់ស្របដែរថាការបញ្ជាក់ពី ក.ស.

---

[1] ប្រតិចារឹក, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E1/87.1, ទំព័រ ៤៦-៤៨ (ភាសាអង់គ្លេស)។

[2] *សូមមើល* វិធាន ២៥ ដែលចែងថា៖

> ១. នៅគ្រប់កាលៈទេសៈដែលអាចធ្វើទៅបាន *នៅពេលសហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេត សួរយកចម្លើយពីជនសង្ស័យ ឬជនត្រូវចោទ ត្រូវតែថតយកសំឡេង ឬ ថតរូបភាពបន្ថែមពីលើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរយកចម្លើយនេះ។* ...
>
> ២. ការសួរយកចម្លើយអាចត្រូវបានធ្វើឡើងដោយមិនចាំបាច់មានការថតសំឡេង ឬ ថតជារូបភាព នៅពេលណាដែលកាលៈទេសៈរារាំងចំពោះការថតនេះ។ *ក្នុងករណីនេះ មូលហេតុដែលមិនអាចធ្វើការថតបានក្នុងពេលសួរយកចម្លើយត្រូវចុះក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ* ហើយជនដែលត្រូវបានសួរយកចម្លើយ ត្រូវទទួលបាននូវឯកសារចម្លងមួយច្បាប់នៃចម្លើយរបស់ខ្លួន។ *ចម្លើយទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងកំណត់ហេតុសួរយកចម្លើយ និងបើអាចធ្វើទៅបាន ត្រូវមានហត្ថលេខា ឬស្នាមម្រាមដៃរបស់អ្នកដែលត្រូវបានស្តាប់ចម្លើយ ឬ សួរចម្លើយ*។ (គូសបញ្ជាក់បន្ថែម)

ច.ស ជាការចាំបាច់[3] ហើយអង្គជំនុំជម្រះសាលាដំបូងបានស្នើភាគីឲ្យដាក់សារណារបស់ខ្លួន[4]។

## I. ប្រវត្តិ

១. មុនពេលសួរសំណួរទៅ អឿន តាន នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ មេធាវីការពារក្តីបានស្តាប់ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយរបស់គាត់កាលពីថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ ដែលមិនទាន់ត្រូវបានធ្វើប្រតិចារឹកសម្រាប់ភាគីនៅឡើយ។ នៅក្នុងខ្សែអាត់សំឡេងនោះ អឿន តាន បានរំឭកអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ថា គាត់បានឆ្លើយសំណួរទាំងនេះរួចហើយ។ ជាការឆ្លើយតបវិញ អ្នកស៊ើបអង្កេតម្នាក់បាននិយាយថា៖ "ប៉ុន្តែចង់ឲ្យអ៊ំរៀបរាប់ឡើងវិញ ដោយសារតែម្សិលមិញហ្នឹង ខ្ញុំអត់បានថតសំឡេងអីទុកអ៊ីចឹង"[5]។ ដោយសារពុំមានកំណត់ហេតុនៅក្នុងសំណុំរឿងពីការស្តាប់ចម្លើយរបស់ ក.ស.ច.ស ជាមួយ អឿន តាន នាថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ នោះ មេធាវីការពារក្តីបានសួរគាត់ពាក់ព័ន្ធនឹងបញ្ហានេះ ដើម្បីឲ្យមានភាពច្បាស់លាស់ផង និងតម្លាភាពផង។

២. នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ នៅពេលមេធាវីការពារក្តីកំពុងសួរសំណួរនោះ អឿន តាន បាននិយាយឲ្យដឹងជាលើកដំបូងថា អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានសួរគាត់នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ពេញមួយថ្ងៃ មុនពេលមានការស្តាប់ចម្លើយដោយបានធ្វើកំណត់ហេតុជាសំឡេងនៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ ជាមួយអ្នកស៊ើបអង្កេតដដែល[6]។ ខុសពីការស្តាប់ចម្លើយលើកទីពីរ កិច្ចសម្ភាសន៍សួរនិងឆ្លើយលើកទីមួយពុំបានធ្វើកំណត់ហេតុជាសំឡេងទេ[7]។

៣. អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានរៀបចំកំណត់ហេតុសង្ខេបមួយដោយផ្អែកលើការស្តាប់ចម្លើយ

---

[3] ប្រតិចារឹក, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E1/87.1, ទំព័រ ៥៣ (ភាសាអង់គ្លេស)។

[4] *ដូចខាងលើ* ទំព័រ ៥៤ (ភាសាអង់គ្លេស)។

[5] ប្រតិចារឹកមួយផ្នែកនៃការស្តាប់ចម្លើយ អឿន តាន ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ D107/2.1, ទំព័រ ៥។ *សូមមើលផងដែរ* ប្រតិចារឹក, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E1/87.1, ទំព័រ ៤៨ (ភាសាអង់គ្លេស)។

[6] ប្រតិចារឹក, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E1/87.1, ទំព័រ ៤៦-៤៨ (ភាសាអង់គ្លេស)។

[7] *ដូចខាងលើ* ទំព័រ ៤៨ (ភាសាអង់គ្លេស)។

ដោយបានធ្វើកំណត់ហេតុថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ និងបានដាក់កំណត់ហេតុសង្ខេបនេះក្នុងនាមជាកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ[8]។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ក៏បានដាក់របាយការណ៍មួយទៅ ក.ស.ច.ស ដែរ ដោយសង្ខេបពីការស្តាប់ចម្លើយរបស់ខ្លួនជាមួយ អឿន តាន[9]។ ទាំងកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ទាំងរបាយការណ៍របស់អ្នកស៊ើបអង្កេតដែលផ្ញើទៅ ក.ស.ច.ស ពុំបានលើកឡើងថា អ្នកស៊ើបអង្កេតបានសួរ ឬបានបង្ហាញឯកសារដល់ អឿន តាន មុនពេលការស្តាប់ចម្លើយដោយបានធ្វើកំណត់ហេតុជាសំឡេងនៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ នោះទេ។

៤. នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ដោយសារមេធាវីការពារក្តីបានសួរដេញដោលអំពីអ្វីដែលអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានសួរគាត់នៅក្នុងកិច្ចសម្ភាសន៍ដោយពុំបានធ្វើកំណត់ហេតុជាសំឡេងនៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ នោះ អឿន តាន ឆ្លើយថា គាត់មិនចាំទេ[10]។ អឿន តាន បានលើកឡើងថា គាត់មានការ "ភាន់ច្រឡំ"[11] និង "ភ្លេចភ្លាំង"[12] នៅពេលគាត់ជួបជាមួយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨។ គាត់មិនអាចនឹកឃើញពីប្រធានបទដែលត្រូវបានយកមកពិភាក្សា នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ទេ ដោយគាត់អះអាងថា៖ "បាទពេលនោះខ្ញុំបានជម្រាបហើយថា លទ្ធភាព និងសមត្ថភាពខ្ញុំឆ្លើយមិនចងចាំទេបាទ។ ភ្លេចមុខ ភ្លេចក្រោយ វង្វេងបាទ"[13]។ គាត់មិនអាចនឹកឃើញថាតើ អ្នកស៊ើបអង្កេតបានបង្ហាញឯកសារ ឬអានឯកសារណាឲ្យគាត់ស្តាប់ដើម្បីរំឭកពីការចងចាំរបស់គាត់ទេ[14]។ នៅពេលមេធាវីការពារក្តីសួរថាតើអ្នកស៊ើបអង្កេតបានព្យាយាមជួយឲ្យគាត់នឹកឃើញឡើងវិញ ដោយផ្តល់ព័ត៌មានដែលអាចមាន

---

[8] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨, ឯកសារ E3/33។

[9] របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៨, ឯកសារ D107/1។

[10] ប្រតិចារឹក, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E1/87.1, ទំព័រ ៤៩ (ភាសាអង់គ្លេស)។

[11] *ដូចយោងខាងលើ* ទំព័រ ៥១ (ភាសាអង់គ្លេស)។

[12] *ដូចយោងខាងលើ*។

[13] *ដូចយោងខាងលើ*។

[14] *ដូចយោងខាងលើ* ទំព័រ ៤៩-៥១ (ភាសាអង់គ្លេស)។

សារៈសំខាន់សម្រាប់ការស្តាប់ចម្លើយដែលបានធ្វើកំណត់ហេតុជាសំឡេង នៅថ្ងៃបន្ទាប់ឬទេ អឿន តាន ឆ្លើយថា៖ "អានេះ ខ្ញុំពិបាកឆ្លើយណាស់បាទ"[15]។

៥. នៅពេលបញ្ចប់សក្ខីកម្មរបស់ អឿន តាន សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា ការបញ្ជាក់ពីកិច្ចសន្ទនារវាង អឿន តាន ជាមួយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស "នឹងស្វែងរកការពិត ព្រោះថាឥឡូវនេះ គឺមានការសង្ស័យដែលថា មានទាក់ទងទៅនឹងការថតសំឡេង ក៏ដូចជាកំណត់ត្រា"[16]។ សហព្រះរាជអាជ្ញាបានធ្វើសំណើផ្ទាល់មាត់ទៅអង្គជំនុំជម្រះសាលាដំបូង សុំប្រតិចារឹកនៃការស្តាប់ចម្លើយថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ និងសុំការបញ្ជាក់ពី ក.ស.ច.ស ថាតើមានកំណត់ហេតុនៃកិច្ចសម្ភាសន៍នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ឬទេ[17]។ មេធាវីការពារក្តីបានយល់ស្របទៅនឹងសំណើនេះ[18] ហើយប្រធានអង្គជំនុំជម្រះថៅក្រម និល ណុន ក៏បានស្នើភាគីឱ្យដាក់សារណារបស់ខ្លួនជាលាយលក្ខណ៍អក្សរលើបញ្ហានេះ[19]។

## II. ច្បាប់ និង ទឡ្ហីករណ៍

៦. ការស្តាប់ចម្លើយដោយសង្ខេបធ្វើឡើងដោយ ក.ស.ច.ស ចំពោះសាក្សី អឿន តាន គឺគ្រាន់តែជាការលេងល្បិចភ្នែក៖ កំណត់ហេតុសង្ខេបនេះបានបំភាន់អង្គជំនុំជម្រះសាលាដំបូង និងភាគីឱ្យគិតថាព័ត៌មានដែល អឿន តាន ផ្តល់ឱ្យគឺកើតចេញពីការចងចាំរបស់គាត់ដោយឯកឯង ឬពុំមានជំនួយពីអ្នកផ្សេងទេចំពោះព្រឹត្តិការណ៍នានា។ កាលៈទេសៈនៃការស្តាប់ចម្លើយដែលមានធ្វើកំណត់ហេតុជាសំឡេងនេះបង្ហាញថា វាត្រូវបានគេរៀបចំ និងមានផែនការជាមុនរួចទៅហើយ។

---

[15] *ដូចយោងខាងលើ* ទំព័រ ៥១ (ភាសាអង់គ្លេស)។

[16] ប្រតិចារឹក, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E1/87.1, ទំព័រ ៥៣ (ភាសាអង់គ្លេស)។

[17] *ដូចយោងខាងលើ*។

[18] *ដូចយោងខាងលើ*។

[19] *ដូចយោងខាងលើ* ទំព័រ ៥៤ (ភាសាអង់គ្លេស)។

៧. ដោយសារ អឿន តាន ទទួលស្គាល់ថាគាត់ភាន់ច្រឡំ និងភ្លេចភ្លាំងក្នុងពេលកិច្ចសម្ភាសន៍នោះ[20] ការស្តាប់ចម្លើយដែលបានធ្វើឡើងបន្ទាប់ពីកិច្ចសម្ភាសន៍ពេញមួយថ្ងៃ ដោយពុំបានធ្វើកំណត់ហេតុជាសំឡេងនេះទំនងជាមានការបង្ហាញឯកសារ និង/ឬ ព័ត៌មាននានាដល់រូបគាត់ ដើម្បីធ្វើឲ្យគាត់នឹកឃើញសាជាថ្មី ឬ ជួយសម្រួលនូវការចងចាំថ្មីៗដែលនឹងត្រូវបានស្រង់យកជាការចងចាំ "ថ្មីៗ" វិញ។ និយាយម្យ៉ាងទៀតគឺថា តាមរយៈកិច្ចសម្ភាសន៍សួរនិងឆ្លើយដោយពុំបានថតសំឡេងរបៀបលាក់លៀមនេះ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានរៀបចំដើម្បីគ្រប់គ្រង និងបើចាំបាច់គឺ បង្កើតសក្ខីកម្មសម្រាប់ អឿន តាន តែម្តង។

៨. សម្រាប់ជាចេតនា និងគោលបំណងទាំងអស់វិញគឺថា កិច្ចសម្ភាសន៍ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ គឺជាកិច្ចសម្ភាសន៍សួរនិងឆ្លើយសាកល្បង ដែលត្រូវបានបង្កើតឡើង និងអនុវត្តដើម្បីជះឥទ្ធិពល/រៀបចំចម្លើយឲ្យ អឿន តាន សម្រាប់ផ្តល់បទសម្ភាសន៍សួរនិងឆ្លើយដែលនឹងត្រូវធ្វើកំណត់ហេតុជាសំឡេង និងដែលរំពឹងថាគាត់នឹងចុះហត្ថលេខារបស់ខ្លួនក្រោមសម្បថថា នោះគឺជាកិច្ចសម្ភាសន៍ដែលឆ្លុះបញ្ចាំងនូវការពិត និងភាពសុក្រឹត្យអំពីការចងចាំរបស់គាត់។ ពុំអាចមានការពន្យល់ណាផ្សេងពីនេះអំពីមូលហេតុដែលអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស នឹងរៀបចំកិច្ចសម្ភាសន៍សួរនិងឆ្លើយពេញមួយថ្ងៃ ដែលពុំបានថតសំឡេង ឬដែលពួកគេមិនបានបង្ហាញឲ្យដឹង នៅមុននឹងការស្តាប់ចម្លើយដែលនឹងត្រូវធ្វើកំណត់ហេតុជាសំឡេងនោះទេ។

៩. អង្គជំនុំជម្រះសាលាដំបូងត្រូវស្នើឲ្យមានការបញ្ជាក់ពី ក.ស.ច.ស ទាក់ទិននឹងកិច្ចសម្ភាសន៍ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨។ សុចរិតភាព និងភាពជឿជាក់បាននៃកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ប៉ះពាល់ដល់លទ្ធភាពរបស់លោក អៀង សារី ក្នុងការពិនិត្យភស្តុតាងដាក់បន្ទុក និងការការពារក្តី។ ដោយដឹងថា អង្គជំនុំជម្រះសាលាដំបូង និងភាគីពឹងផ្អែកលើកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ជាពិសេសដោយសារថា សាក្សី

[20] *ដូចយោងខាងលើ* ទំព័រ ៥១ (ភាសាអង់គ្លេស)។

បានចុះហត្ថលេខាដោយគ្មានការជំទាស់នោះ[21] អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយជាមួយ អៀង តាន ដែលមិនពេញលេញ មិនសុក្រឹត្យ និងនាំឲ្យភាន់ច្រឡំ។

១០. ប្រសិនបើ អៀង តាន មិនបាននិយាយឲ្យដឹងពីខ្សែអាត់សំឡេងដែលគាត់បានឆ្លើយសំណួរដែលគេសួរ *រួចហើយ*នោះ[22] *និង* ប្រសិនបើមេធាវីការពារក្តីមិនបានបំពេញការងាររបស់ខ្លួនយ៉ាងយកចិត្តទុកដាក់ និងមិនបានស្តាប់ខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ និងដោយគ្រាន់តែពឹងផ្អែកលើចម្លើយដោយសង្ខេប ដែលធ្វើឡើងដោយ ក.ស.ច.ស នោះ ម្ល៉េះសមមេធាវីការពារក្តី (និងតាមពិតគឺ អង្គជំនុំជម្រះសាលាដំបូង និងភាគី ផងដែរ) នឹងមិនបានដឹងពីការស្តាប់ចម្លើយដែលមិនបានធ្វើកំណត់ហេតុជាសំឡេង/កិច្ចសម្ភាសន៍រៀបចំមុនបែបនេះទេ។

១១. គួរកត់សម្គាល់ថា នេះពុំមែនជាបញ្ហាតិចតួចដែលត្រូវបដិសេធចោល ហើយចាត់ទុកវាថាជាយុទ្ធសាស្ត្រការពារក្តីនៃការបន្ទុចបង្អាក់កិច្ចដំណើរការនីតិវិធីតុលាការនោះទេ។ ដូចដែលកំណត់ហេតុបានបង្ហាញថា ជាច្រើនលើកច្រើនគ្រា នៅពេល អៀង តាន មានការលំបាកដោយសារការភ្លេចភ្លាំង ឬភាពសុក្រឹត្យនៅក្នុងចម្លើយដែលគាត់បានផ្តល់ឲ្យ ក.ស.ច.ស នោះ សហព្រះរាជអាជ្ញាបានសុំឲ្យគាត់ផ្ទៀងផ្ទាត់ថា តើគាត់ឯកភាពទៅនឹងចម្លើយដែលគាត់បានផ្តល់ឲ្យអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ថាពិតប្រាកដ និងសុក្រឹត្យ ឬយ៉ាងណានោះ[23]។

---

[21] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ, ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨, ឯកសារ E3/33, ទំព័រ ១២ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* ប្រតិចារឹក, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារ E1/23.1, ទំព័រ ២១-២៣ នៅពេលចៅក្រម Lavergne សួរសាក្សី ឡុង នរិន្ទ អំពីកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់គាត់ ដែល ឡុង នរិន្ទ បានចុះហត្ថលេខា និងផ្តិតមេដៃ (ទំព័រ ២២-២៣) (ភាសាអង់គ្លេស) និងដែលចៅក្រម Lavergne បានសុំឲ្យចាត់ទុកថា ជាជាចម្លើយដែល "សុទ្ធចិត្ត និងត្រឹមត្រូវ" នៃចម្លើយរបស់គាត់នៅចំពោះមុខអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស (ទំព័រ ២៣) (ភាសាអង់គ្លេស)។

[22] ប្រតិចារឹកមួយផ្នែកនៃការស្តាប់ចម្លើយ អៀង តាន ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ D107/2.1, ទំព័រ ៤ (ភាសាអង់គ្លេស)។

[23] ប្រតិចារឹក, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E1/86.1, ទំព័រ ៤៩-៥២, ៦០-៦១ (ភាសាអង់គ្លេស)។

១២. វាហួសពីការស្តីបន្ទោសទៅទៀតដែលថា ចម្លើយរបស់ អឿន តាន បានមកដោយមធ្យោបាយទុច្ចរិត និងថា សក្ខីកម្មរបស់គាត់ក្នុងពេលសវនាការ ដែលភាគច្រើនផ្អែកលើចម្លើយនេះ គឺគួរឲ្យសង្ស័យ។ ចំណុចនេះនាំឲ្យមានបញ្ហាចោទពីតម្លៃជាភស្តុតាងនៃសក្ខីកម្មរបស់គាត់ ជាពិសេសក្នុងករណីដែលគាត់ឯកភាពទៅតាមខ្លឹមសារនៃចម្លើយជាលាយលក្ខណ៍អក្សរថា ជាភស្តុតាងគោលផ្ទុយទៅនឹងសក្ខីកម្មរបស់គាត់ក្នុងពេលសវនាការ[24]។

១៣. រដ្ឋធម្មនុញ្ញ[25] កិច្ចព្រមព្រៀង[26] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[27] វិធាន ២១ និង មាត្រា ១៤ នៃ

[24] *សូមមើល ដូចយោងខាងលើ* ទំព័រ ៦០-៦១ (ភាសាអង់គ្លេស)។

[25] រដ្ឋធម្មនុញ្ញ, មាត្រា ៣១៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"; *ដូចយោងខាងលើ* មាត្រា ១២៨ ដែលចែងថា អំណាចតុលាការ "ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ"។

[26] កិច្ចព្រមព្រៀង, មាត្រា ១២(២) ចែងថា អង្គជំនុំជម្រះវិសាមញ្ញ "ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ"; *ដូចយោងខាងលើ* មាត្រា ១៣ (១)៖ "សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រូវបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិ៖ … ពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុក"។

[27] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៣ ថ្មី៖ "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និង … ទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ … [និង]ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ ដូចមានចែងក្នុងមាត្រា ១៤ និង ១៥ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ"; *ដូចយោងខាងលើ* មាត្រា ៣៥ថ្មី ដែលរួមជាមួយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងបានចែងថា៖ "នៅក្នុងចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាដូចខាងក្រោម៖ … ង.ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានឹងភស្តុតាងដាក់បន្ទុកដែរ"។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[28] បានធានាដល់លោក អៀង សារី នូវសិទ្ធិសវនាការប្រកបដោយយុត្តិធម៌ និងតម្លាភាព ដែលរួមមានសិទ្ធិពិនិត្យដេញដោលភស្តុតាងប្រឆាំងនឹងរូបគាត់ និងការការពារខ្លួនទៀតផង។ លោក អៀង សារី មិនអាចទទួលបានសវនាការប្រកបដោយយុត្តិធម៌ទេ ហើយដំណើរការតុលាការក៏មិនមានតម្លាភាពដែរ ប្រសិនបើភស្តុតាងដែលដាក់ជូនអង្គជំនុំជម្រះសាលាដំបូងជាភស្តុតាងមិនអាចជឿជាក់បាន និងមិនពេញលេញ។

១៤. ការខកខានដោយចេតនារបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ក្នុងការពុំបានដឹងអំពីអត្ថិភាពនៃកិច្ចសម្ភាសន៍សួរនិងឆ្លើយដោយពុំបានធ្វើកំណត់ហេតុសំឡេងជាមួយនឹង អឿន តាន ធ្វើឲ្យមានមន្ទិលយ៉ាងខ្លាំង ទៅលើភាពគួរឲ្យជឿជាក់បាននៃកំណត់ហេតុនៃការស្តាប់ចម្លើយ។ ប្រសិនបើពុំមានកំណត់ហេតុនៃកិច្ចសម្ភាសន៍សួរនិងឆ្លើយនៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ នោះទេ មេធាវីការពារក្តី *ពុំដឹងនិងមិនអាចដឹង*អំពីសំណួរដែល អឿន តាន់ ត្រូវបានគេសួរ និងចម្លើយរបស់គាត់ទៅនឹងសំណួរនៅថ្ងៃនោះឡើយ។ មេធាវីការពារក្តី*ពុំដឹង និងមិនអាចដឹង*ថាតើអ្នកស៊ើបអង្កេតបានប្រើប្រាស់ឯកសារណាមួយ ឬធ្វើសេចក្តីថ្លែងការណ៍ណាមួយដើម្បីជួយជំរុញ ឬធ្វើឲ្យ អឿន តានមានការនឹកឃើញឡើងវិញនោះឡើយ។ មេធាវីការពារក្តី *ពុំដឹង និងមិនអាចដឹង*ឡើយ ថាតើមានភាពខុសគ្នា ឬភាពមិនស្របគ្នាជាសត្យានុម័ត ឬយ៉ាងណា រវាងចម្លើយរបស់គាត់នៅក្នុងកិច្ចសម្ភាសន៍ដំបូង និងកិច្ចសម្ភាសន៍ដោយមានកំណត់ហេតុជាសំឡេងដែលបានធ្វើឡើងនៅថ្ងៃបន្ទាប់នោះ។ បញ្ហាទាំងនេះប៉ះពាល់ដល់សមត្ថភាពរបស់លោក អៀង សារី ក្នុងការពិនិត្យភស្តុតាងដាក់

---

[28] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤(១), ១៤(៣)(ឃ-ង) ដែលត្រូវបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់និងនីតិវិធីនៅ អ.វ.ត.ក ចែងថា៖

> (១) ... ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ... (៣) ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញដូចខាងក្រោម៖ ... (ឃ) ដើម្បី ... ការពារខ្លួនដោយខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន ... (ង) ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។

បន្ទុក និងបង្ហាញសណ្ឋានការពារខ្លួន ប៉ះពាល់ដល់ការថ្លឹងថ្លែងឲ្យបានសមស្របទៅនឹង ចម្លើយរបស់ អឿន តាន និងពិតណាស់ទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ និងប៉ះពាល់ដល់សមត្ថភាព របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកការពិតនៅក្នុងសំណុំរឿង ០០២/០១។

១៥. តំណាងសហព្រះរាជអាជ្ញាបានផ្តួចផ្តើមឲ្យមានសំណើសុំការបញ្ជាក់ពី ក.ស.ច.ស ទៅលើបញ្ហានេះ[29]។ តំណាងសហព្រះរាជអាជ្ញាស្នើឡើងបែបនេះ បន្ទាប់ពីស្តាប់ការធ្វើសក្ខីកម្មរបស់ អឿន តាន និងទទួលស្គាល់ថា ដំណោះស្រាយទៅលើក្តីមន្ទិលចំពោះថាតើមានអ្វីបានកើតឡើងនៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ និងថាតើអ្វីទៅដែលបានដាក់នៅក្នុងកំណត់ហេតុនោះ នឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកការពិត[30]។ មេធាវីការពារក្តីបានបញ្ជាក់ការគាំទ្ររបស់ខ្លួនចំពោះសំណើនេះ[31]។ អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យភាគីនានាដាក់សារនាររបស់ខ្លួន[32] ដោយទទួលស្គាល់យ៉ាងពេញលេញថា វិធាន ៧៦(៦) ចែងថា ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។

១៦. នេះមិនមែនជាលើកទីមួយឡើយ ដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យភាគីនានាដាក់សារណាទៅលើបញ្ហានេះ[33]។ ហើយនេះក៏មិនមែនជាលើកទីមួយឡើយ ដែលមេធាវីការពារក្តីបានលើកឡើងនូវក្តីកង្វល់អំពីភាពខុសគ្នា និងភាពមិនស្របគ្នាជាសត្យានុម័តរវាងចម្លើយសាក្សីរបស់ ក.ស.ច.ស និងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ។ បន្ថែមទៅលើសារណាដែលបានលើកឡើងនៅក្នុងសំណើនេះ មេធាវីការពារក្តីសូមដាក់បញ្ចូល និងបន្ថែមនូវមូលដ្ឋាន ហេតុផល និងព័ត៌មាន

---

[29] ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E1/87.1 ទំព័រ ៥៣ (ភាសាអង់គ្លេស)។

[30] ដូចយោងខាងលើ ទំព័រ ៥៣ (ភាសាអង់គ្លេស)។

[31] ដូចយោងខាងលើ។

[32] ដូចយោងខាងលើ ទំព័រ ៥៤ (ភាសាអង់គ្លេស)។

[33] សូមមើលប្រតិចារឹក ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/100.1 ទំព័រ ៨៦ (ភាសាអង់គ្លេស) ដែលនៅក្នុងនោះលោកប្រធាន និល ណុន បានទទួលស្គាល់ថា ភាពមិនប្រក្រតីនៅក្នុងការស្តាប់យកចម្លើយសាក្សី ភី ភួន គឺជា "បញ្ហាសំខាន់ មិនមែនជាបញ្ហាធម្មតាទេ" ហើយស្នើឲ្យមេធាវីការពារក្តីធ្វើជាសំណើលាយលក្ខណ៍អក្សរ។

សាវតារពីគ្រប់សារណាមុនៗទាំងអស់ ទាក់ទិននឹងភាពខុសគ្នា និងភាពមិនស្របគ្នាជាសត្យានុម័ត រវាងចម្លើយសាក្សីរបស់ ក.ស.ច.ស និងខ្សែអាត់សំឡេងនៃការស្ដាប់ចម្លើយ[34]។

១៧. កន្លងមក អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានស្នើសុំឲ្យមានការបញ្ជាក់ពី ក.ស.ច.ស ទាក់ទិននឹងសំណើរបស់ ក.ស.ព ស្ដីពីអត្ថិភាពនៃឯកសារ។ ឧទាហរណ៍ ក.ស.ព ថ្មីៗនេះបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកសេចក្ដីបញ្ជាក់ពី ក.ស.ច.ស អំពីស្វ័យជីវប្រវត្តិរបស់សាក្សី[35]។ អង្គជំនុំជម្រះសាលាដំបូងគួរតែអនុវត្តដូចគ្នាដែរនៅត្រង់ចំណុចនេះ។ អំណាចនៃការអនុវត្តបែបនេះមានចែងនៅក្នុងវិធាន ៩៣។

១៨. អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មានចេតនាផ្ដល់នូវព័ត៌មានពិតតែពាក់កណ្ដាលប៉ុណ្ណោះ ដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានា។ អង្គជំនុំជម្រះសាលាដំបូងមិនអាចស្វែងរកការពិតបានឡើយ

---

[34] សំណើរបស់ អៀង សារី សុំស្ដាប់ការបង្ហាញភ័ស្ដុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្ដាប់ចម្លើយសាក្សី ភី ភួន លើកទីពីររបស់ ក.ស.ច.ស ដែលកើតមាននូវភាពមិនប្រក្រតី ដែលអាចនឹងចាត់ទុកថាជាការលេងផ្ដិតភ្នែក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E221។ លិខិតពីក្រុមមេធាវីការពារក្ដី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការជំទាស់ទៅនឹងចម្លើយសាក្សី" ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E96/7/1។ លិខិតពីមេធាវីការពារក្ដី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ច្របូកច្របល់/បាត់ឯកសារជាសំឡេងនៅក្នុងសំណុំរឿង" ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១២។ លិខិតពីមេធាវីការពារក្ដី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សំណើសុំខ្សែអាត់ថតសំឡេង/វីដេអូ អំពីការស្ដាប់ចម្លើយសាក្សីមួយចំនួនរបស់ ក.ស.ច.ស" ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១២។

[35] សូមមើល សំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨៧(៤) សុំឲ្យទទួលយកឯកសារចំនួនបី ដែលបានសរសេរដោយសាក្សី TCW-694 ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E216 កថាខណ្ឌ ៩-១២។ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ជូនតាមសំណើ និងបានផ្ញើអនុស្សរណៈមួយទៅឲ្យ ក.ស.ច.ស ដោយស្នើសុំនូវឯកសារថតចម្លងមួយច្បាប់ដើម្បីដាក់នៅក្នុងសំណុំរឿង។ សូមមើលអនុស្សរណៈពីអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សំណើទៅសហចៅក្រមស៊ើបអង្កេតស្នើសុំឯកសារដែលសហព្រះរាជអាជ្ញាបានស្នើសុំនៅសវនាការ"(ឯកសារ E216) ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E216/1។ ក.ស.ច.ស បានអនុវត្តតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង និងបានដាក់ឯកសារនៅក្នុងសំណុំរឿង។ សូមមើលលិខិតពីសហចៅក្រមស៊ើបអង្កេតជាតិ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សំណើសុំឯកសារនិក្ខេបបទរបស់សាក្សី សួង ស៊ីគឿន ក្រោមចំណងជើងថា 'Itineraire dún intellectual Khmer Rouge'" ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E216/2។

នៅក្នុងសំណុំរឿង ០០២/០១ ហើយការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌មិនអាចកើតមានឡើយ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង និងភាគីនានាទទួលបាននូវព័ត៌មានមិនពេញលេញ និង មិនត្រឹមត្រូវ ទាក់ទិននឹងកាលៈទេសៈដែលសាក្សីត្រូវបានស្តាប់យកចម្លើយនោះ។ ទោះបីជាការ ទទួលបាននូវសេចក្តីបញ្ជាក់ពី ក.ស.ច.ស អាចធ្វើឲ្យមានការមិនសប្បាយចិត្ត និងអាចធ្វើ ឲ្យមានឥទ្ធិពលអវិជ្ជមានទៅលើ ក.ស.ច.ស និងអ្នកស៊ើបអង្កេត ដែលពាក់ព័ន្ធយ៉ាងណាក៏ដោយ ក៏ការបញ្ជាក់ការពិតគឺជាការចាំបាច់ និងសមហេតុផលសម្រាប់ការធ្វើសេចក្តីសម្រេចដ៏ត្រឹមត្រូវ និងយុត្តិធម៌នៃដំណើរការនីតិវិធីទាំងនេះ។ នៅក្នុងចំណុចនេះ ជាថ្មីម្តងទៀត គួរតែមានការរំឭក ឡើងវិញនូវអ្វីដែលចៅក្រម Louis D. Brandeis នៃតុលាការកំពូលសហរដ្ឋអាមេរិក បានធ្វើការ កត់សម្គាល់យ៉ាងត្រឹមត្រូវថា "ពន្លឺព្រះអាទិត្យត្រូវបានចាត់ទុកថាជាសារធាតុសម្លាប់មេរោគ ដ៏ប្រសើរបំផុត"[36]។

## III. សេចក្តីសន្និដ្ឋាន និងសំណូមពរ

១៩. ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូង នៅតែបន្តផ្អែកទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយថា ជាចម្លើយមាន "សុទ្ធចិត្ត និងត្រឹមត្រូវ" ស្របទៅនឹងចម្លើយរបស់សាក្សី[37] ទោះបីជាមានការចង្អុល បង្ហាញពីមេធាវីការពារក្តី អំពីភាពមិនប្រក្រតីនៅក្នុងការស្តាប់យកចម្លើយយ៉ាងណាក៏ដោយនោះ នឹងនាំឲ្យមានការមន្ទិលសង្ស័យយ៉ាងខ្លាំងទៅលើសុចរិតភាពនៃការជំនុំជម្រះក្តី។ តាមរយៈការចាត់ វិធានការជាក់លាក់ទៅលើបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងនឹងបង្ហាញដល់ភាគីនានា និង សាធារណជន (ដែលមានសារៈសំខាន់ជាពិសេសសម្រាប់គោលបំណងនៃកេរដំណែល) ថា

---

[36] សូមមើលលិខិតពីមេធាវីការពារក្តី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "កិច្ចប្រជុំរៀបចំសវនាការក្នុងពេលឆាប់ៗខាងមុខនេះ" ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១២ ដោយសកស្រង់ U.S. Supreme Court Justice Louis D. Brandeis, *Other People's Money*, Harper's Weekly ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩១៣ អាចរកមើល បាននៅគេហទំព័រ៖ http://www.law.louisville.edu/library/collections/brandeis/node/191 (ចូលមើលចុងក្រោយនៅ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១២)។

[37] សូមមើល ឧទាហរណ៍ ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E1/23.1 ទំព័រ ២១-២៤ (ភាសាអង់គ្លេស)។

អង្គជំនុំជម្រះប្តេជ្ញា ធានានូវយុត្តិធម៌ផ្នែកនីតិវិធី និងយុត្តិធម៌ពិតប្រាកដសម្រាប់គ្រប់ភាគីទាំងអស់ និងធានានូវសិទ្ធិក្នុង ទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ និងលើកកម្ពស់តម្លាភាព។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. ស្នើសុំការបញ្ជាក់ពី ក.ស.ច.ស ទាក់ទិននឹង៖

i. តើមានកំណត់ហេតុជាសំឡេង វីដេអូ និង/ឬ ជាលាយលក្ខណ៍អក្សរនៃកិច្ចសម្ភាសន៍ កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ឬទេ។

ii. រយៈពេលនៃកិច្ចសម្ភាសន៍សួរនិងឆ្លើយនោះ។

iii. បុគ្គលដែលមានវត្តមាននៅពេលនោះ។

iv. ឯកសារ និងសម្ភារៈផ្សេងទៀត ដែលអ្នកស៊ើបអង្កេត ក.ស.ច.ស បានបង្ហាញដល់ អៀង តាន ប្រសិនបើមាន។

v. ប្រសិនបើគ្មានកំណត់ហេតុជាសំឡេង ឬវីដេអូនោះទេ សូមបញ្ជាក់ពីមូលហេតុដែលពុំបានធ្វើកំណត់ហេតុ និងពីមូលហេតុនៃការសួរ អៀង តាន ពេញមួយថ្ងៃដោយពុំបានធ្វើកំណត់ហេតុជាសំឡេងអំពីការសាកសួរនោះ មុនពេលមានការស្តាប់ចម្លើយដោយមានកំណត់ហេតុជាសំឡេង។ និង

ខ. ប្រសិនបើពិតជាមានកំណត់ហេតុជាសំឡេង វីដេអូ និង/ឬ ជាលាយលក្ខណ៍អក្សរនៃកិច្ចសម្ភាសន៍ កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ សូមដាក់កំណត់ហេតុនោះនៅក្នុងសំណុំរឿង ដើម្បីឲ្យភាគីនានាអាចពិនិត្យមើល និងប្រើប្រាស់បាន។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

_______________ _________________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តីលោក អៀង សារី

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានា**ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២**